**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស

៣៣ ✵ ៧៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ១៩៩៤ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស សម្រាប់ផ្តល់ជូនពលករកម្ពុជាធ្វើការនៅ បរទេស ដូចមានគំរូឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា ២.-**

លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ជាឯកសារសម្រាប់ធ្វើដំណើរឆ្លងដែនពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេស ដែលពលករកម្ពុជាទទួលបានការអនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការងារជាផ្លូវការ។

**មាត្រា ៣.-**

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងមានសិទ្ធិដកហូត ឬបដិសេធនូវលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងករណីប្រើប្រាស់ខុសគោលដៅ ឬក្លែង ឬបាត់។

**មាត្រា ៤.-**

លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសមានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ ដោយមិនអាចពន្យាសុពលភាពបានឡើយ។

**មាត្រា ៥.-**

នីតិវិធី បែបបទ នៃការចេញ ការដកហូត ឬការបដិសេធលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៦.-**

ការបង់ថ្លៃសេវារដ្ឋបាលលើការចេញលិខិតធ្វើដំណើរពលករធ្វើការនៅបរទេសជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសពលករ និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងមហាផ្ទៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៧.-**

ជនណាដែលក្លែងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ឬកាន់កាប់ ឬប្រើប្រាស់ លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសក្លែងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**មាត្រា ៨.-**

លិខិតឆ្លងដែនធម្មតាគឺនៅមានតម្លៃ និងប្រើប្រាស់ក្នុងការចេញទៅធ្វើការនៅបរទេសរហូតដល់ផុតសុពលភាព។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរព ជម្រាបជូន
សម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រី ក្រសួង ការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




COVER PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages


Invisible ink
2D
Barcode information
Guilloche Patterns
Full color inkjet print
Invisible
Personalized
Information
(IPI)
Holographic Image (Laminate)
Secret Mark design
Red. Invisible on Laminate
Micro Text
KINGDOMOFCAMBODIA
Name in Khmer XXX
Profession WORKER
Height 153 CM
Distinguishing marks A SCAR ABOVE THE RIGHT SIDE OF MOUTH
Signature of bearer
Signature and seal
T0000000
ព្រះរាជាណាចក្រកម្ពុជា KINGDOM OF CAMBODIA
Travel Document
Type TD
Country Code KHM
Travel Document No. T0000000
Surname XXX
Given names XXX
Nationality CAMBODIAN
Date of birth 03 FEB 1986
Sex M
Place of birth TAKEO
Date of issue 03 AUG 2012
Authority MIN PHNOM PENH
Date of expiry 03 AUG 2015
TDKHMXXX<<XXX<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<<
T0000000<8KHM8602031M15080310083276<<<<<<84
Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages
DATAPAGE

2

## កូនដែលយកតាម
## Accompanied Children

| នាមត្រកូលនិងនាមខ្លួន<br>Surname/Given names | ភេទ<br>Sex | ថ្ងៃខែឆ្នាំកំណើត<br>Date of birth |
| --- | --- | --- |
| 1. | | |
| 2. | | |
| 3. | | |

1 2 3

0000000T

3

## សេចក្តីសំគាល់
## Notices

T0000000

# ACCOMPANIED CHILDREN AND NOTICES PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages

4

ទិដ្ឋាការ
Visas



0000000T

5

ទិដ្ឋាការ
Visas



T0000000

VISAS PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages




VISAS PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages


Invisible Security Thread
Secret Mark design
Hidden image Level 1
Hidden image Level 2 (ODD PAGE)
ទិដ្ឋាការ
Visas
Micro Text Numbering
Invisible ink
ទិដ្ឋាការ
Visas
Perforation running number book
Hidden image Level 2 (EVEN PAGE)
pattern design
VISAS PAGE
inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages

10

ទិដ្ឋាការ
Visas

ទិដ្ឋាការ
Visas

11

0000000T T0000000

VISAS PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages




VISAS PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages

14

ទិដ្ឋាការ
Visas

ទិដ្ឋាការ
Visas

15

0000000T

T0000000

# VISAS PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages

16

ទិដ្ឋាការ
Visas

Invisible ink

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ អនុញ្ញាតឲ្យអ្នកកាន់លិខិតធ្វើដំណើរនេះ ធ្វើដំណើរ ចេញ-ចូលដោយសេរី និងគ្មានឧបសគ្គ ព្រមទាំងជួយជ្រោមជ្រែង និងការពារក្នុងករណីចាំបាច់។

The Minister of Ministry of Interior of the Kingdom of Cambodia, requests all those whom it may concern to allow the bearer to pass freely, and to afford the bearer any such assistance and protection as may be necessary.

Invisible ink

T0000000

T0000000

Barcode running number book

# INNER BACK COVER PAGE

Inside print by mill water mark paper CBS1 grade with visible fiber & Invisible fiber weight 92 gsm 16 pages